# កម្ពុជា:  វាយប្រហារលើសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិនយោបាយ

---

**A LICADHO Briefing Paper**
**January 2006**


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស  លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦

សេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិប្រជាធិបតេយ្យនានាកំពុងស្ថិតក្រោមការគំរាមកំហែងដ៏ធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជាដោយរដ្ឋាភិបាលនៅតែបន្តប្រើប្រាស់តុលាការដើម្បីចាប់អ្នករិះគន់ និងអ្នកនយោបាយលេចធ្លោមួយចំនួនដាក់ពន្ធនាគារ ។ សកម្មជនសិទ្ធិមនុស្សសំខាន់ៗ អ្នកសារព័ត៌មាន និងប្រធានសហជីព ព្រមទាំងសមាជិកសភាគណៈបក្សប្រឆាំងត្រូវបានក្លាយជាគោលដៅក្នុងការចាប់បន្តបន្ទាប់យកទៅផ្តន្ទាទោស ដែលផ្តួចផ្តើមដោយរដ្ឋាភិបាល ។

ខណៈពេលសរសេររបាយការណ៍នេះ ជន៤រូបកំពុងស្ថិតក្នុងពន្ធនាគារនាទីក្រុងភ្នំពេញរង់ចាំការវិនិច្ឆ័យទោសក្រោមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដែលជាបទល្មើសព្រហ្មទណ្ឌទាក់ទងទៅនឹងការបញ្ចេញមតិ យោបល់ជំទាស់នឹងរដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាល ហើយជនទីប្រាំម្នាក់ទៀតក៏ត្រូវបានឃុំខ្លួនដែរ ប៉ុន្តែត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នវិញ ។ យ៉ាងហោចណាស់ក៏មានមនុស្សប្រាំមួយនាក់ទៀតដែរ ដែលបានភៀសខ្លួនចេញពីកម្ពុជា ឬពុំទាន់ហ៊ានវិលត្រឡប់មកវិញតាមការគ្រោងទុកឡើយ ដើម្បីជៀសវាងពីការចាប់ចងពីបទចោទប្រកាន់ស្រដៀងគ្នានេះ ។ ប្រធានគណៈបក្សប្រឆាំង ដែលបានចាកចេញពីកម្ពុជាអស់រយៈពេលជិតមួយឆ្នាំកន្លងមក ក្រោយពីការដកហូតអភ័យឯកសិទ្ធិរបស់គាត់ហើយថ្មីៗនេះ ត្រូវបានកាត់ទោសដោយកំបាំងមុខឱ្យជាប់ពន្ធនាគាររយៈពេល ១៨ ខែ ពីបទបរិហារកេរ ។ លើសពីនេះទៀត សមាជិកជាន់ខ្ពស់សភាមកពីគណៈបក្សប្រឆាំងម្នាក់កំពុងជាប់ពន្ធនាគារប្រាំពីរឆ្នាំ បន្ទាប់ពីមានការកាត់ទោសដែលប្រកបដោយការរិះគន់យ៉ាងទូលំទូលាយ ក្រោមការចោទប្រកាន់ពីបទលួចបង្កើតកងទ័ពខុសច្បាប់ដោយតុលាការយោធា ។

ការផ្តន្ទាទោសបទបរិហារកេរ្តិ៍ និងពាក្យចរចាមអារាមទូទៅពីការប្រុងចាប់ និងឃុំឃាំងបានបណ្តាលឱ្យមានការខ្លាចរអារ ដោយអង្គការសង្គមស៊ីវិលនានា និងស្ថាប័នផ្សេងៗទៀតកំពុងមានការភ័យខ្លាចកាន់តែខ្លាំងឡើងៗចំពោះការបញ្ចេញមតិទាក់ទិននឹងរដ្ឋាភិបាល ។

ការចាប់ចងនេះ បានបង្កើនឱ្យមានការខ្វាយខ្វល់កាន់តែខ្លាំងជាងមុនអំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងកិច្ចការតុលាការនៅកម្ពុជា ។ រាល់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌបរិហារកេរ្តិ៍ថ្មីៗកន្លងទៅនេះ ត្រូវបានផ្អែកទៅលើបណ្តឹងដែលប្តឹងដោយរដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាល។ ភាគច្រើនមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការបញ្ចេញមតិទាក់ទិននឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃគណបក្សប្រជាជនកម្ពុជា ដែលមានអំណាចយ៉ាងខ្លាំង និងជាពិសេសការរិះគន់ចំពោះរដ្ឋាភិបាលអំពីបញ្ហាចម្រុងចម្រាស់ព្រំដែនកម្ពុជា-វៀតណាម ។

ការបង្រ្កាបលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដែលធ្វើឡើងក្រោយពីមានការហាមប្រាមដ៏តឹងរឹងអស់រយៈពេលបីឆ្នាំនូវសិទ្ធិនៃការជួបប្រជុំគ្នា ជាការកត់សំគាល់ឱ្យឃើញនូវការរអិលថយក្រោយនូវលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងការខិតខំប្រឹងប្រែងក្នុងការលើកស្ទួយសិទ្ធិមនុស្ស នីតិរដ្ឋ និងឯករាជភាពនៃតុលាការ ។ ជំហានជោគជ័យដ៏លំបាកលំបិន ដែលខិតខំដើម្បីឆ្ពោះទៅរកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យពហុបក្ស រួមទាំងសង្គមស៊ីវិលដ៏សកម្ម ប្រព័ន្ធសារព័ត៌មានដ៏រស់រវើក និងគណបក្សប្រឆាំង ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងរាល់សង្គមប្រជាធិបតេយ្យ ទាំងអស់នេះកំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់ដែលនឹងអាចបាត់បង់ ។

## ជនទាំងឡាយដែលត្រូវបានចាប់ខ្លួនមកដល់ពេលនេះ

- លោក ម៉ម សូណង់ដូ ជាម្ចាស់ និងនាយកស្ថានីយ៍វិទ្យុសំបុកឃ្មុំឯករាជ្យត្រូវចាប់ខ្លួនកាលពី ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៥ ដោយបានផ្សាយនូវការសំភាសន៍មួយជាមួយនឹងសកម្មជនព្រំដែនកម្ពុជានៅប្រទេសបារាំង ដែលបានរិះគន់ចំពោះសន្ធិសញ្ញាព្រំដែនកម្ពុជា-វៀតណាម ដែលចុះហត្ថលេខាដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ បទសំភាសន៍នោះត្រូវបាន ចាក់ផ្សាយកាលពីថ្ងៃទី ២០ កញ្ញា ឆ្នាំ ២០០៥ មុនពេលដែលលោក ហ៊ុន សែន បានចុះហត្ថលេខាលើសន្ធិសញ្ញានៅថ្ងៃទី ១០ តុលា ។ ក្នុងឱកាសសំភាសន៍ដែលគាត់ធ្វើសំភាសន៍ផ្ទាល់ លោក ម៉ម សូណង់ដូ ពុំបានបញ្ចេញមតិរិះគន់សន្ធិសញ្ញាឡើយ ហើយជាច្រើនលើកច្រើនសារជំទាស់នឹងទស្សនៈអ្នកដែលគាត់សំភាសន៍នេះ ។ ជាដំបូងលោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់ក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជាពីបទបរិហារកេរ្តិ៍[១] (ដែលអនុវត្តការដាក់ពន្ធនាគារអតិបរមាមួយឆ្នាំ) ហើយក្រោយមកចោទ

---

[1] រដ្ឋាភិបាលប្តឹងពីបទបរិហារកេរក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៩២ (ហៅថាច្បាប់ព្រហ្មទណ្ឌអន្តរកាល) ពុំបានប្តឹងបទរដ្ឋប្បវេណី ក្រោមច្បាប់ស្តីពីសារព័ត៌មានទេ ។ ការប្រើប្រាស់មាត្រាបរិហារកេរព្រហ្មទណ្ឌដោយរដ្ឋាភិបាលប្រឆាំងនឹងសារពត៌មានបានបណ្តាលឱ្យមានការរិះគន់ក្នុងរយៈកាលកន្លងមក ការតស៊ូមតិដើម្បីឱ្យមានសេរីភាពសារព័ត៌មានបានលើកឡើងថា ច្បាប់សារព័ត៌មានមានមាត្រាគ្រប់គ្រាន់ ហើយមាត្រាទាំងនោះ រួមមានការបង្រួញបញ្ហាតុលាការ និងសំណងជាប្រាក់ជាដើម ក៏ដូចជាការកែតម្រូវកំហុសធ្ងន់ធ្ងរនានាចំពោះសារពត៌មានជាដើម។

ប្រកាន់ពីបទការផ្សាយព័ត៌មានមិនពិត (រហូតដល់បីឆ្នាំ) និង"បទញុះញង់ឱ្យអ្នកដទៃប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដោយពុំមានបទល្មើសព្រហ្មទណ្ឌណាមួយត្រូវបានប្រព្រឹត្តឡើយ" (ដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំ) ។ ការចោទប្រកាន់នេះគឺជាលទ្ធផលនៃការប្តឹងគាត់ដោយរដ្ឋាភិបាល និងរដ្ឋសភាជាតិ។

លោក ភីតឋី លយប្រែកតី តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានពិពណ៌នាថា ការចាប់ខ្លួនលោក ម៉ម សូណង់ដូ ដោយខុសនីតិវិធី[២] ដោយការចាប់នេះផ្អែកទៅលើ "លិខិតស្នើចាប់ខ្លួនរបស់តុលាការ" ដែលចេញដោយតុលាការរាជធានីភ្នំពេញ ។ លិខិតបែបនេះអាចនឹងចេញឱ្យចាប់ត្រឹមត្រូវតាមច្បាប់បាន អាស្រ័យដោយជនជាប់ចោទនោះពុំបានមកតាមការបង្គាប់របស់តុលាការបន្ទាប់ពីបានទទួលដីកាកោះត្រឹមត្រូវ ហើយនៅតែមិនទៅជួបទៀតនោះ ។ តំណាងអង្គការសហប្រជាជាតិក៏បានធ្វើការកត់សំគាល់ផងដែរថា លោក ម៉ម សូណង់ដូ ត្រូវបានឃុំក្នុងពន្ធគារតាមបញ្ជារបស់ចៅក្រមម្នាក់ ដែលពុំបានផ្តល់ការពន្យល់ផ្អែកច្បាប់ទាល់តែសោះចំពោះការសម្រេចចិត្តឃុំខ្លួនរបស់គាត់ ដូចដែលច្បាប់កម្ពុជាតម្រូវ ឱ្យធ្វើឡើយ ។ សំណួរជាច្រើនត្រូវបានសួរចំពោះការចោទប្រកាន់បន្ថែមលើលោក ម៉ម សូណង់ដូ នូវបទព្រហ្មទណ្ឌដោយចោទប្រកាន់ថាលោកបានធ្វើការញុះញង់ ។ ក្រោម ច្បាប់កម្ពុជា ការចោទប្រកាន់ពីការញុះញង់ត្រូវតែទាក់ទងទៅនឹងបទឧក្រិដ្ឋជាក់លាក់ណាមួយដែលស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌ ។ មកដល់ពេលនេះគេនៅតែមិនទាន់ដឹងច្បាស់នៅឡើយថាតើលោក ម៉ម សូណង់ដូ បានញុះញង់អោយមានបទឧក្រិដ្ឋប្រភេទណាមួយកើតឡើងនោះទេ គ្មានចំណុចណាមួយនៅក្នុងសេចក្តីសំភាសន៍របស់គាត់ជាមួយនឹងសកម្មជនកម្ពុជានៅប្រទេសបារាំងនោះបានញុះញង់ឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋណាមួយឡើយ ។

- លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ត្រូវបានចាប់ខ្លួននៅថ្ងៃទី ១៥ តុលា ឆ្នាំ២០០៥ នៅខេត្តបន្ទាយមានជ័យខណៈដែលលោកព្យាយាមឆ្លងដែនចូលទៅប្រទេសថៃដើម្បីស្វែងរកសិទ្ធិជ្រកកោន ។ លោកត្រូវបានចាប់ខ្លួនដោយសារពាក់ព័ន្ធនឹង

[2] សេចក្តីថ្លែងការណ៍ថ្ងៃទី ២០ តុលា ២០០៥ ដោយលោក ភីតឋី លយប្រែកតី តំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។

ការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ថ្ងៃទី១១ ខែតុលា ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃ្លាំមើល ៣ នាក់ទៀត ដែលជាក្រុមប្រឹក្សាចម្រុះសហជីពកម្មករ និងសមាគម ។ សេចក្តីថ្លែងការណ៍នោះទាក់ទងទៅនឹងការចុះហត្ថលេខារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លើសន្ធិសញ្ញាព្រំដែនកម្ពុជា-វៀតណាម ។ លោក រ៉ុង ឈុន ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងការញុះញង់ឱ្យអ្នកដទៃប្រព្រឹត្តបទឧក្រិដ្ឋ ដោយគ្មានបទឧក្រិដ្ឋណាមួយត្រូវ បានប្រព្រឹត្តឡើយ ។ រដ្ឋាភិបាលបានប្តឹងគាត់ និងមនុស្សបីនាក់ទៀតដែលបានចុះហត្ថ លេខាលើសេចក្តីថ្លែងការណ៍ថ្ងៃទី ១១ តុលា ។

លោក ភីតចឺ លយប្រែកតឺ តំណាងពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានធ្វើការពិពណ៌នាថា ការចាប់ខ្លួនលោក រ៉ុង ឈុន គឺជាការខុសនីតិវិធី ហើយសំអាងហេតុផលដូចការចាប់ខ្លួនលោក ម៉ម សូណង់ដូ ដែរ ។ បេសកជនអង្គការសហប្រជាជាតិរូបនោះបានលើកឡើងនូវសំណួរសួរថា ហេតុអ្វីបានជាគេចោទលោក រ៉ុង ឈុន ពីបទញុះញង់ដោយបានធ្វើការកត់សំគាល់ថា "ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា" ដែលបានចេញសេចក្តីថ្លែងការណ៍ថ្ងៃទី១១ តុលា នោះ ពុំមានចំណុចណាដែលលើកឡើងនូវអំពើណាមួយដែលអាចបកស្រាយថាជាបទល្មើសព្រហ្មទណ្ឌបានឡើយ[៣] ។

- លោក កឹម សុខា ប្រធានមជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស ជាអង្គការមិនមែនរដ្ឋាភិបាលមួយត្រូវបានចាប់ខ្លួននៅភ្នំពេញកាលពីថ្ងៃទី ៣១ ធ្នូ ឆ្នាំ២០០៥ កន្លងទៅនេះ ។ គាត់ត្រូវបាន ចាប់ខ្លួនដោយសារការទាក់ទងទៅនឹងខ្លឹមសារ ដែលបានសរសេរលើបដាចងនៅខាងមុខតូបតាំងពិពណ៌របស់អង្គការគាត់ក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ដែលបានប្រារព្ធធ្វើនៅភ្នំពេញ ។ បដានោះជាបដាដែលត្រូវបានចងនៅគ្រប់ទីកន្លែង ពេលដែលមជ្ឈមណ្ឌលកម្ពុជា ដើម្បីសិទ្ធិមនុស្សរៀបចំធ្វើវេទិកាសាធារណៈនៅទូទាំងប្រទេសក្នុងកំឡុងពេលបោះឆ្នោតជាតិឆ្នាំ២០០៣ កន្លងមក ដោយមានអក្សរសរសេរដៃតូចៗជាពាក្យរបស់ប្រជាពលរដ្ឋកម្ពុជាដែលបានបញ្ចេញមតិអំពីបញ្ហានយោបាយ ។ ពាក្យបែបនេះដែលគេបានចោទប្រកាន់ថា ជាការរិះគន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និង សំដៅនិយាយថា កម្ពុជាបានបាត់បង់ទឹកដីទៅខាងវៀតណាម ។

លោក កឹម សុខា ក៏ត្រូវបានចាប់ខ្លួនដូចលោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុនដែរ ដោយផ្អែកលើលិខិតស្នើសុំចាប់ខ្លួនរបស់តុលាការចេញដោយតុលាការរាជធានី

---

[3] សេចក្តីថ្លែងការណ៍ ថ្ងៃទី ២០ តុលា ដោយលោក ភីតចឺ លយប្រែកតឺ ។

ភ្នំពេញ ។ គាត់ត្រូវបានចោទពីបទបរិហារកេរ្តិ៍យោងតាមបណ្តឹងរបស់រាជរដ្ឋាភិបាល ។ (ទន្ទឹមនឹងបទបរិហារកេរ្តិ៍ដែរ រដ្ឋាភិបាលបានចោទប្រកាន់ដោយគ្មានភស្តុតាងពីបទញុះញង់ ហើយពេលនេះក៏នៅមិនទាន់ច្បាស់ដែរថា តើគាត់ត្រូវបានចោទប្រកាន់ពីបទនេះឬយ៉ាងណានៅថ្ងៃមុខនោះទេ។)

- លោក យេង វីរៈ ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ត្រូវបានចាប់ខ្លួននៅក្នុងថ្ងៃតែមួយជាមួយលោក កឹម សុខា ដែរ ដោយហេតុផលចោទប្រកាន់ដូចគ្នា ។ លោក យេង វីរៈ គឺជាប្រធានគណៈកម្មការរៀបចំនៃក្រុមសង្គមស៊ីវិល ដែលបានរៀបចំទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ។ គាត់ត្រូវបានចាប់ខ្លួនយោងតាមលិខិតស្នើសុំចាប់ខ្លួនរបស់តុលាការក្រោយពីមានបណ្តឹងរបស់រាជរដ្ឋាភិបាល ហើយត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ។
- លោក ប៉ា ងួនទៀង នាយកផ្នែកវិទ្យុនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស ត្រូវបានចាប់ខ្លួននៅខេត្តស្ទឹងត្រែងជិតព្រំដែនឡាវ កាលពីថ្ងៃទី ៤ មករា ឆ្នាំ ២០០៦ កន្លងទៅនេះ ក្រោមការចោទប្រកាន់ពាក់ព័ន្ធនឹងការចងបដាក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ នោះ។ តាមរបាយការណ៍បានឱ្យដឹងថា គាត់ត្រូវបានចាប់ខ្លួនតាមបញ្ជារបស់ក្រសួងមហាផ្ទៃ ហើយពុំមានការបង្ហាញដីកាបញ្ជាឱ្យចាប់ខ្លួន ឬលិខិតស្នើសុំចាប់ខ្លួនពីតុលាការឡើយ ។ អ្នកនាំពាក្យរដ្ឋាភិបាលបាននិយាយថា លោក ប៉ា ងួនទៀង គ្រាន់តែនាំខ្លួន "ដើម្បីសាកសួរនិងពិភាក្សាតែប៉ុណ្ណោះ" ដោយបានបន្ថែមថា នៅថ្ងៃចាប់ខ្លួននោះលោកពុំទាន់ត្រូវបានចោទប្រកាន់ពីបទណាមួយឡើយ។ លោក ប៉ា ងួនទៀង ត្រូវបាននាំមកតុលាការរាជធានីភ្នំពេញនៅថ្ងៃបន្ទាប់មក ហើយគាត់ក៏ត្រូវបានចោទប្រកាន់នៅថ្ងៃនោះដែរ ។

ទាំងអស់គ្នា ក្នុងចំណោមជនខាងលើកំពុងត្រូវបានឃុំខ្លួននៅពន្ធនាគារព្រៃសរភ្នំពេញ ដើម្បីរង់ចាំការវិនិច្ឆ័យទោស ។ តុលាការរាជធានីភ្នំពេញបានបដិសេធការសុំដោះលែង លោក ម៉ម សូណង់ដូ លោក រ៉ុង ឈុន និងលោក កឹម សុខា ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន (ហើយចំពោះករណីលោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុន សាលាឧទ្ធរណ៍ក៏បានបដិសេធការសុំដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ននេះដែរ) ។ លោក យេង វីរៈ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នកាលពីថ្ងៃទី ១១ មករា ២០០៦ កន្លងទៅនេះ ក្រោយពីមានការរិះគន់យ៉ាងខ្លាំងពីសំណាក់អន្តរជាតិ និងក្នុងប្រទេសពីរលកនៃការចាប់ចងឥតប្រណីនេះ ។ ក្នុងខណៈពេល

សរសេរនេះការស្នើសុំឱ្យដោះលែងលោក ជា ងួនទៀង ឱ្យនៅក្រៅឃុំបណ្តោះអាសន្ននៅមិនទាន់បានដាក់ជូនតុលាការនៅឡើយទេ ។

ការចាប់ចងទាំងនេះ បានបណ្តាលឱ្យមានការថ្កោលទោសជាច្រើន រួមមានទាំងមន្ត្រីអង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក និងរដ្ឋាភិបាលនានា ធនាគារពិភពលោក ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានាថែមទៀតផង។

## *មនុស្សដែលអាចត្រូវចាប់ខ្លួនប្រសិនបើត្រឡប់មកកម្ពុជាវិញ*

មនុស្សទាំង ៦ នាក់ ខាងក្រោមនេះ ដែលបច្ចុប្បន្នមិនស្ថិតនៅក្នុងប្រទេសកម្ពុជាទេ ពួកទាំងនោះប្រាកដជានឹងត្រូវចាប់ និងឃុំខ្លួនប្រសិនបើពួកគេត្រឡប់មកកម្ពុជាវិញ ដោយត្រូវបានចោទពីបទបរិហារកេរ្តិ៍ និង/ឬពាក់ព័ន្ធនឹងការចោទប្រកាន់ ក្រោយពីមានបណ្តឹងរបស់រដ្ឋាភិបាល។

- លោក អៀ ចាន់ណា អគ្គលេខាធិការរងចលនានិស្សិត ដើម្បីលទ្ធិប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ជាមួយលោក រ៉ុង ឈុន និងមនុស្សមួយចំនួនទៀត ។ លោក អៀ ចាន់ណា បានភៀសខ្លួនទៅប្រទេសថៃ ដើម្បីស្វែងរកសិទ្ធិជ្រកកោនពីសំណាក់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ហើយរដ្ឋាភិបាលកម្ពុជាបានដាក់សំណើសុំទៅប្រទេសថៃ ដើម្បីឱ្យធ្វើបត្យាប័ណ្ណ (បញ្ជូនមកវិញ) គាត់មកកម្ពុជាវិញដើម្បីធ្វើការចោទប្រកាន់។
- លោក ម៉ែន ណាត ប្រធានសមាគមមន្ត្រីរាជការឯករាជកម្ពុជា ដែលបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ថ្ងៃទី ១១ តុលា ។ មែន ណាត បានភៀសខ្លួនទៅប្រទេសថៃ ហើយរដ្ឋាភិបាលកម្ពុជាក៏បានស្នើធ្វើបត្យាប័ណ្ណពីប្រទេសថៃផងដែរ ។
- លោក ជា មុនី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា[4] ជាមនុស្សទីបួនដែលបានចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មានថ្ងៃទី ១១ តុលា ។ គាត់គេចពីការ

[4] លោក ជា មុនី ជាអ្នកទទួលតំណែងជាប្រធានសហជីព បន្ទាប់ពីបងប្រុសរបស់គាត់ត្រូវធ្វើឃាតកាលពីខែ មករា ឆ្នាំ២០០៤ កន្លងទៅ ។ ក្នុងខែ សីហា ឆ្នាំ ២០០៥ បុរសពីរនាក់ត្រូវបានកាត់ឱ្យជាប់ពន្ធនាគារ ដោយបានចោទថាបានធ្វើឃាតលោក ជា វិជ្ជា ហើយការកាត់ទោសនេះត្រូវទទួលការរិះគន់យ៉ាងខ្លាំងដោយពុំមានភស្តុតាងគ្រប់គ្រាន់ ។ ការកាត់ទោសនោះ គឺត្រូវបានផ្អែកស្ទើរតែទាំងស្រុងទៅលើចម្លើយសារភាពរបស់ជនជាប់ចោទម្នាក់ទៀត ដែលក្រោយមកគាត់បានបដិសេធសេចក្តីសារភាពនោះវិញ ដោយបាននិយាយថានគរបាលបានវាយដំគាត់ដើម្បីឱ្យគាត់ឆ្លើយសារភាពបែបនេះ ។ ក្នុងសវនាការសាក្សីជាច្រើនបានជួយផ្តល់ ការអះអាងចំពោះជនជាប់ចោទម្នាក់នេះ ដោយបានបញ្ជាក់ថា ក្នុងថ្ងៃកើតហេតុនោះគាត់កំពុងស្ថិតនៅក្នុងភូមិមួយដែលមានចម្ងាយជាង ៥០ គីឡូម៉ែត្រពីកន្លែងកើតហេតុ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី គាត់ និងជនម្នាក់ទៀតដែលត្រូវចោទដែរនោះ ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ២០ ឆ្នាំ ។

ចាប់ខ្លួនដោយសារគាត់បានទៅចូលរួមសន្និសិទអ្នកការពារសិទ្ធិមនុស្សនៅអឺរ៉ុបក្នុងខណៈដែលមានបណ្តឹងលើរូបគាត់ ហើយក៏បន្តនៅទីនោះតទៅទៀតតែម្តង ។

- លោក សៀន ប៉េងសែ សកម្មជនកម្ពុជារស់នៅប្រទេសបារាំងដែលបានសំភាសន៍តាមវិទ្យុសំបុកឃ្មុំដោយលោក ម៉ម សូណង់ដូ នាំឱ្យមានការចាប់ខ្លួននៅពេលក្រោយ។ លោក សៀន ប៉េងសែ គឺជាអតីតរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មកម្ពុជា ហើយបច្ចុប្បន្នជាប្រធានគណៈកម្មាធិការព្រំដែនកម្ពុជាជាអង្គការឯកជនមួយ ដែលមានមូលដ្ឋាននៅទីក្រុងប៉ារីស ដែលតាមឃ្លាំមើលបញ្ហាព្រំដែននានា ។
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ លេខាផ្ទាល់របស់អតីតព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ ដែលបានសរសេរអំពីយោបល់របស់ទ្រង់អំពីបញ្ហាព្រំដែនចុះផ្សាយតាមគេហទំព័ររបស់ព្រះមហាវីរៈក្សត្រនរោត្តម សីហនុ ។ ព្រះអង្គម្ចាស់ ធម្មិកោ បានភព្រះកាយភៀសទៅប្រទេសចិន ។
- លោក បណ្ឌិត សាយ បុរី អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា និងជាអតីតប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ មានសេចក្តីរាយការណ៍មកថា តុលាការរាជធានីភ្នំពេញក៏បានចេញដីកាឱ្យនគរបាលតាមរកចាប់ និងឃុំខ្លួនលោកបណ្ឌិត សាយ បុរី ដើម្បីសាកសួរក្រោមការចោទប្រកាន់ពីបទឃប់ឃិតផ្តល់ព័ត៌មានមិនពិតទាក់ទង នឹងយោបល់របស់លោកអំពីបញ្ហាព្រំដែនកម្ពុជា-វៀតណាម ។ បច្ចុប្បន្ននេះគាត់កំពុងស្នាក់នៅក្រៅប្រទេស ។

## *ការផ្តន្ទាទោសមន្ត្រីគណៈបក្សប្រឆាំង សម រង្ស៊ី*

ចាប់តាំងពីមានការបង្កើតរដ្ឋាភិបាលចម្រុះរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វុនស៊ិនប៉ិចមក[5] គណបក្ស សម រង្ស៊ី ត្រូវបានក្លាយជាគោលដៅក្នុងការផ្តន្ទាទោសពីបទព្រហ្មទណ្ឌនានា ។ អភ័យឯកសិទ្ធិរបស់សមាជិកសភាតំណាងរាស្រ្តគណបក្ស សម រង្ស៊ី បីរូប រួមទាំងប្រធាន សម រង្ស៊ី ផងដែរ ត្រូវបានដកហូតកាលពីខែ កុម្ភៈ ២០០៥ កន្លងទៅ ហើយក្រោយពីនោះមកក៏មានការផ្តន្ទាទោសលើអ្នកទាំងបីរូបនោះ :

[5] រដ្ឋាភិបាលថ្មីត្រូវបានបង្កើតឡើងកាលពីខែ កក្កដា ឆ្នាំ ២០០៤ មួយឆ្នាំក្រោយពីមានការជាប់គាំងផ្នែកនយោបាយ ដែលគណបក្សហ្វុនស៊ិនប៉ិច ដែលធ្លាប់បានបង្កើតរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជនកម្ពុជា តាំងពីឆ្នាំ១៩៩៣ បានចងសម្ព័ន្ធភាពជាមួយនឹងគណបក្សប្រឆាំង សម រង្ស៊ី ហើយបានទាត់ចោលកិច្ចខិតខំប្រឹងប្រែងរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការបង្កើតរដ្ឋាភិបាលចម្រុះថ្មីមួយ ។ ជាយថាហេតុ ហ្វ៊ុនស៊ិនប៉ិច ក៏បានបន្ទន់ឥរិបទ បែកបាក់សម្ព័ន្ធភាពជាមួយ សម រង្ស៊ី ហើយបែរទៅបង្កើតរដ្ឋាភិបាលជាមួយគណបក្សប្រជាជនកម្ពុជាវិញ ។

- លោក ជាម ចន្នី ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ៧ ឆ្នាំ កាលពីខែ សីហា ២០០៥ កន្លងទៅនេះ ដោយបានចោទលោកពីបទលួចបង្កើតកងទ័ពខុសច្បាប់ ។ ការផ្តន្ទាទោសនេះគឺមានការជាប់ពាក់ព័ន្ធជាមួយនឹងការបង្កើតក្រសួងក្នុងរដ្ឋាភិបាលស្រមោលរបស់គណៈបក្ស សម រង្ស៊ី ដោយយកគំរូតាមគណៈបក្សប្រឆាំងនៅប្រទេសអង់គ្លេស អូស្ត្រាលី និងប្រទេស សភាប្រជាធិបតេយ្យមួយចំនួនទៀតដើម្បីតាមឃ្លាំមើលការអនុវត្តន៍ ការងាររបស់រដ្ឋាភិបាល ។

  លោក ជាម ចន្នី ជាអ្នកដឹកនាំក្រសួងដែលពាក់ព័ន្ធនឹងកិច្ចការយោធា និងសន្តិសុខ ដែលការផ្តន្ទាទោសបានចោទប្រកាន់លោកថា បានបង្កើតកងកម្លាំងខុសច្បាប់ ។ នៅក្នុងសវនាការនោះតុលាការពុំបានបង្ហាញភស្តុតាងជាអាវុធយុទ្ធភ័ណ្ឌ ឬផែនការប្រព្រឹត្តអំពើហិង្សា ណាមួយឡើយ ។ គាត់ត្រូវបានកាត់ទោសដោយខុសច្បាប់នៅក្នុងតុលាការយោធាកម្ពុជា ដែលពុំមានយុត្តាធិការលើជនស៊ីវិលដូចជាគាត់នោះឡើយ ។ ចៅក្រមបានបដិសេធមិនឱ្យសាក្សីការពារគាត់ចូលធ្វើសក្ខីកម្មឡើយ ព្រមទាំងមិនអនុញ្ញាតមេធាវីការពារក្តីគាត់សួរដេញដោលចំពោះភស្តុតាងដាក់បន្ទុកលើរូបគាត់ទេ ។ ក្រុមការងារនៃអង្គការសហប្រជាជាតិបានបញ្ជាក់ថា ការឃុំខ្លួនលោក ជាម ចន្នី គឺជាការឃុំឃាំងតាមអំពើចិត្ត ព្រមទាំងជា ការរំលោភលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ លោក ជាម ចន្នីត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារយោធាកម្ពុជា ដែលមានអ្នកទោសធ្ងន់ធ្ងរនៃរបប ខ្មែរក្រហម ឈ្មោះ តា ម៉ុក ត្រូវឃុំនៅទីនោះដែរ ។

- លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងដែលបានភៀសខ្លួនពីកម្ពុជា ក្រោយពេលដែលគេបានដកអភ័យឯកសិទ្ធិរបស់គាត់ ហើយពុំទាន់ហ៊ានត្រឡប់មកកម្ពុជាទេ ដោយខ្លាចការចាប់ចងឥតត្រាប្រណីនេះ ត្រូវបានកាត់ទោសដោយកំបាំងមុខ ក្រោមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ កាលពីថ្ងៃទី ២២ ធ្នូ ២០០៥ កន្លងទៅនេះ។ គាត់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារសរុប ១៨ខែ និងពិន័យជាប្រាក់ចំនួន ១៤.០០០ ដុល្លារ ជាសំណងជម្ងឺចិត្តចំពោះ ការចោទប្រកាន់ពីរករណីពីបទបរិហារកេរ្តិ៍នេះ ។ ការចោទប្រកាន់ទីមួយពាក់ព័ន្ធនឹងរឿង ក្តីដែលគាត់បានប្តឹងសម្តេច ហ៊ុន សែន ចោទ

ប្រកាន់ថា ហ៊ុន សែន ជាអ្នកទទួលខុសត្រូវ ក្នុងព្រឹត្តិការណ៍គប់គ្រាប់បែកលើគណបក្ស សម រង្ស៊ី ដែលបណ្តាលឱ្យមានមនុស្សស្លាប់យ៉ាងរង្គាលក្នុងបាតុកម្មមួយនារាជធានីភ្នំពេញ កាលពីខែ មិនា ឆ្នាំ១៩៩៧ កន្លងទៅ។ ការចោទប្រកាន់ទីពីរពាក់ព័ន្ធទៅនឹងការចោទប្រកាន់ជាសាធារណៈរបស់លោក សម រង្ស៊ី ចំពោះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច គឺទ្រង់ នរោត្តម រណឫទ្ធិ ថាទ្រង់បានទទួលសំណូកដើម្បីយល់ព្រមក្នុងការបង្កើតរដ្ឋាភិបាលចម្រុះជាមួយនឹងគណបក្សប្រជាជនកម្ពុជា ក្រោយការបោះឆ្នោតសកលឆ្នាំ ២០០៣ កន្លងទៅ ។

- លោក ជា ប៉ូច បច្ចុប្បន្នកំពុងប្រឈមមុខនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ទ្រង់ នរោត្តម រណឫទ្ធិ ថាបានទទួលសំណូកដើម្បីបង្កើតរដ្ឋាភិបាលចម្រុះ ។ បច្ចុប្បន្ននេះ គាត់នៅមានសេរីភាពនៅឡើយដោយការពន្យាការបើកសវនាការ ។